# ការសម្ភាសរបស់អ្នកមីង រឿង ណារី

**កៈ អ្នកសម្ភាសឈ្មោះជាង ស៊ីអ៊ាង** **ខៈ អ្នកទទួលការសម្ភាសឈ្មោះ រឿង ណារី**

## ការសង្ខេបប្រវត្តិរបស់អ្នកមីង រឿង ណារី

អ្នកមីងរឿងណារីមានអាយុ៥២ ឆ្នាំនៅក្នុងឆ្នាំ២០២០ មានភេទស្រី ទីលំនៅបច្ចុប្បន្ននៅភូមិទូលរកា ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងខ្ញុំជាដំបូងខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំពិភាក្សាជាមួយមីងទាក់ទងពីប្រវត្តិរបស់មីង ហើយការសម្ភាសទាំងអស់ហ្នឹងត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹង ជាពិសេសខ្ញុំពិភាក្សាជាមួយមីងទុកអោយកូនរបស់មីងរឺមួយក៏ចៅៗរបស់មីងបានស្គាល់បានដឹងពីប្រវត្តិរបស់មីងដែរមីងបានរៀបរាប់ ចឹងសំរាប់មីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសម្ភាសមួយហ្នឹងទៅក្នុងវេបសាយសាលាទេមីង?

ខៈ ព្រមយល់ព្រម។

កៈ បាទមីងបាទចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសមីងខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវហើយថ្ងៃខែដែរខ្ញុំសម្ភាសមីងគឺនៅថ្ងៃទី២៧ខែ៧ឆ្នាំ២០២០ហើយការសម្ភាសទាំងអស់ហ្នឹង គឺធ្វើឡើងនៅភូមិហ្នឹងគឺភូមិទូលរកាឈោះមីង?

ខៈ ទូលរកា។

កៈ ភូមិទូលរកា ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម?

ខៈ ចា៎!

កៈ ចឹងសំរាប់មីងឈ្មោះពេញរបស់មីងទាំងត្រកូលតាមបញ្ជីជាតិឈ្មោះអីគេមីង?

ខ៖ រឿងណារី។

ក៖ រឿងណារី?

ខ៖ ចាំ!

ក៖ ចុះមានឈ្មោះហៅក្រៅអត់មីង?

ខ៖ ហៅអីប៉ូយៗ។

ក៖ ប៉ូយ?

ខ៖ ចាំប៉ោយប៉ែត្រនោះ។

ក៖ ចុះអើកាលពីក្មេងធ្លាប់មានឪពុកម្ដាយហៅឈ្មោះមីងអីផ្សេងពីហ្នឹងទៀតអត់?

ខ៖ អត់ទេហៅតែចឹងហៅប៉ូយៗហ្នឹង!

ក៖ អ៎ូបាទចុះមីងសព្វថ្ងៃអាយុប៉ុន្មានហើយមីង?

ខ៖ ខ្ញុំអាយុហាពីរ។

ក៖ ហាសិបពីរឆ្នាំ?

ខ៖ ចាំ!

ក៖ ចុះមីងកើតនៅថ្ងៃខែឆ្នាំណាមីងចាំអត់?

ខ៖ អត់ចាំទេក្មួយអើយ!

ក៖ អ៎ូ!

ខ៖ ខែឆ្នាំណុង។

ក៖ អើឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានក៏អត់ចាំដែរណោះមីងណោះ?

ខ៖ អត់ចាំទេៗ។

កៈ អ៊ូ!

ខៈ គ្រាន់តែដឹងថាប្តីអាយុដប់ឆ្នាំអាយុដប់មួយឆ្នាំ។

កៈ ចូលប៉ុលពត?

ខៈ ដឹងតែនៅជាមួយប៉ុលពតតែម៉ង។

កៈ អ៊ូបាទមីង!

ខៈ ហើយនៅក្នុងរបបណុង។

កៈ បាទចុះឆ្នាំច័ន្ទគតិជូត ឆ្លូវ ខាល ថោះមីងឆ្នាំអីគេអាលក្ខណៈជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់ មមី មមែអីហោសមីងឆ្នាំអីគេ?

ខៈ ខ្ញុំឆ្នាំរកា។

កៈ មីងឆ្នាំរកាហោស?

ខៈ ចាំ!

កៈ អ៊ូចុះស្រុកកំណើតដែរមីងកើតម៉ងមីងកើតនៅណា?

ខៈ នៅភូមិគៀនជ្រៃ។

កៈ ភូមិគៀនជ្រៃហោស?

ខៈ ចាំ!

កៈ អ៊ូចុះអើមីងមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់ទៅមីង?

ខៈ ខ្ញុំបួននាក់។

កៈ បួននាក់ចុះមីងកូនទីប៉ុន្មានទៅ?

ខៈ កូនបងគេ។

កៈ អ៊ំចុះមានស្រីប៉ុន្មានប្រុសប៉ុន្មានមីង?

ខៈ ស្រីពីរប្រុសពីរ។

កៈ អ៊ំចុះមីងអាចប្រាប់ដូចជាប្អូនៗរបស់មីងឈ្មោះអីគេខ្លះបានទេមីង?

ខៈ បាន។

កៈ គាត់ឈ្មោះអីខ្លះមីង?

ខៈ បន្ទាប់ពីខ្ញុំមកឈ្មោះគី។

កៈ អ៊ំចុះបន្ទាប់មកទៀត?

ខៈ ឈ្មោះស្រ៊ាន។

កៈ អ៊ំចុះបន្ទាប់មកទៀត?

ខៈ ហិន។

កៈ អ៊ំប្អូននាក់ហ្នឹងណេះមីង?

ខៈ ប្អូននាក់។

កៈ ចុះអើប្អូនរបស់មីងដូចជាទីពីរនៅណាហើយគាត់ធ្វើអីគេទៅមីង?

ខៈ នៅហ្នឹងគាត់វាឥឡូវមុនវាលក់រកស៊ីបន្តិចបន្តួចលក់ត្រីលក់សាច់តាមផ្ទះនេះណុងនៅផ្សារបឹងកុកហ្នឹង ដល់ពេលឥឡូវនៅផ្ទះផ្អាកត្រឹមក្ងុំវិឌហ្នឹង!

កៈ លែងទៅហើយណេះ?

ខៈ មិនសូវទៅទេនៅតែផ្ទះ។

កៈ អ៊ំចឹងគាត់ទៅលក់នៅណាមីងនៅ..?

ខៈ នៅបឹងកុក។

កៈ អ៊ូនៅផ្សារបឹងកុកហោស?

ខៈ ចាំផ្សារបឹងកុក។

កៈ អ៊ូបាទមីងចុះអើបន្ទាប់មកទៀតទីបីគាត់នៅណា?

ខៈ នៅភ្នំពេញ។

កៈគាត់ធ្វើអីគេនៅណុង?

ខៈ វាបើកឡានកាត់ដេរ។

កៈ អ៊ូតែគាត់មានគ្រួសារហើយណេះបងណេះ?

ខៈ មានហើយបានកូនពីរបីហើយ!

កៈ អ៊ូមានចៅមានអីនៅ?

ខៈ អត់មាននៅទេនៅទើបបានកូនអាយុបងអាយុប្រាំបីប្រាំបួនឆ្នាំ។

កៈ អ៊ូ!

ខៈ ប្អូនអាយុមួយខួប។

កៈ រួចចុះពៅគេ?

ខៈ ប្អូនទី...។

កៈ បួន?

ខៈ ហ្នឹងប្អូនទីពៅហើយបើអាមួយទៀតក៏នៅភ្នំពេញដែរលក់ដូរនៅណាដែរអារឿងហោស!

កៈ អ៊ូចឹង..?

ខៈ បានកូនបីដែរ។

កៈ ចុះពួកគាត់មានគ្រួសារអស់ហើយណេះមីង?

ខ៖ មានអស់ហើយបងប្អូនណុងហោស!

ក៖ អ៊ូចុះអើមីងគិតថាមីងធ្លាប់មានជាអនុស្សាវរីយ៍ដែរមីងចងចាំជាមួយគាត់ធ្លាប់ធ្វើអីគេខ្លះជាមួយគាត់ ដូចទៅស្រែធ្វើចំការអីដែរចងចាំហាសមានទេមីង?

ខ៖ មានទៅដើរលក់ដូរដល់ជ្រានដល់ល្ងៀកហ្នឹង ទូលល្អីចង់តាពែកក្បាលហើយក្ជួយអើយទំរាំបានប៉ុននេះហោស!

ក៖ អ៊ូ!

ខ៖ ពីក្មេងមក។

ក៖ ធ្វើអីគេមីងលក់អីគេ?

ខ៖ លក់នុំបញ្ចុំលក់អីហ្នឹងហាស!

ក៖ អ៊ូ!

ខ៖ ទៅខាងស្រែខាងជ្រានហោស!

ក៖ ចឹងមានន័យថាមីងពីមុនមីងធ្វើនុំបញ្ចុះដែរណេះមីង?

ខ៖ ចាំធ្វើនុំបញ្ចុះទៅទូលទៅលក់ណុងទូលស្តុរទៅលក់អីកោះជំនាន់ណុងមានតែជំនាន់ទូលទេជំនាន់អឺហោស!

ក៖ បាទមីង!

ខ៖ មករំលងប្អូនប្រាំប្អូនដប់ឆ្នាំមកមុខមកបានគេរៀងរីកចំរៀនតិចហោស!

ក៖ អ៊ូ!

ខ៖ ទូលវែកស្គាល់តែទូលហើយវែកទេ។

ក៖ ប៉ុន្តែមិនដែរធ្វើស្រែចំការទេ?

ខ៖ ធ្វើស្រែចំការក៏ធ្វើដែរ។

កៈ ជាមួយបងប្អូនហាសណោះមីង?

ខៈ ធ្វើការហ្នឹងជាមួយនៅជាមួយម៉ែហោស!

កៈ ទៅធ្វើជាមួយបងប្អូនអីចឹងទៅ?

ខៈ ហ្នឹងបងប្អូនជុំគ្នាហ្នឹងដល់ពេលគេធំទៅគេមានប្តីប្រពន្ធគេទៅរកស៊ីបែកៗអស់ទៅ។

កៈ អូ៎បាទមីងបាទចឹងមានន័យថាបងប្អូនរបស់មីងនៅឆ្ងាយពីគ្នាទាំងអស់?

ខៈ នៅឆ្ងាយពីគ្នានៅជិតតែប្អូនស្រីមួយហ្នឹង!

កៈ អូ៎!

ខៈ ខ្ញុំនៅទួលរកាវំលងតិច។

កៈ បាទមីងបាទចុះឪពុករបស់មីងឈ្មោះអីគេមីង?

ខៈ ឈ្មោះនៅក្នុងបញ្ជីជាតិឈ្មោះគ្រូរឿង។

កៈ ឈ្មោះអីគេត្រកូលគាត់ឈ្មោះអីគេទៅ?

ខៈ ដឹងឈ្មោះអីទេនេះភ្លេងអាឈ្មោះត្រកូលហាសណោះ!

កៈ ដឹងតែឈ្មោះរឿង?

ខៈ ចាំគាត់ឈ្មោះគ្រូរឿងត្រកូលឈ្មោះអីភ្លេចដែរ។

កៈ អូ៎ចុះម្តាយមីងឈ្មោះអីគេទៅ?

ខៈ គាត់ឈ្មោះសឺហាន។

កៈ សឺហាន?

ខៈ សឿហាន។

កៈ សឿហានអូ៎សឿហានចុះអើទាំងឪពុកទាំងម្តាយគាត់អ្នកស្រុកនៅហ្នឹងតើមីងហោស?

ខ៖ ហ្នឹងហើយគ្រូណុងគាត់នៅអីទេភ្លេចបាត់ហើយវិហារសួរគាត់ហ្នឹងហាស!

ក៖ អូ៎វិហារសួរហោស?

ខ៖ ចា៎។

ក៖ អូ៎!

ខ៖ គាត់នៅវិហារសួរបើម៉ែនៅភូមិគៀនជ្រៃហ្នឹង!

ក៖ បាទមីងបាទរួចចុះអើដូចជាឪពុកម្ដាយឪពុកកាលគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹម..?

ខ៖ គាត់ធ្វើគ្រូ។

ក៖ សំរាប់ចិញ្ចឹមកូនចៅ?

ខ៖ គាត់ធ្វើគ្រូបង្រៀន។

ក៖ តាំងពីដើមម៉ងហោស?

ខ៖ ចា៎គាត់រៀនតាំងពីជំនាន់អាពតមករហូត។

ក៖ អូ៎រួចចុះម្ដាយម្ដាយគាត់ធ្វើអីគេទៅ?

ខ៖ ម៉ែខ្ញុំកសិករហ្នឹង!

ក៖ អូ៎ចុះឪពុកម្ដាយគាត់ស្លូតរឺមួយក៏កាចមីង?

ខ៖ មិនកាចមិនស្លូតទេឪរៀងកាចជាងម៉ែអត់អីទេ។

ក៖ អូ៎បាទមីងបាទមីងគិតថាអើមីងមានសាច់រឿងរឺមួយក៏ជាអនុស្សាវរីយ៍ដែរមីងចងចាំជាមួយម្ដាយឪពុកមីងកាលពួកគាត់ឥឡូវខូចរឺមួយនៅ?

ខ៖ ខូចអស់ហើយ!

ក៖ ខូចអស់ហើយណេះ?

ខ៖ ខូចអស់ដប់បីដប់បួនឆ្នាំ។

ក៖ អូ៎តែមីងមានជាសាច់រឿងដែរមីងចងចាំជាមួយពួកគាត់មានអីគេខ្លះជាមួយពួកគាត់កាលមីងនៅក្មេងៗ?

ខ៖ ធ្លាប់រកអនុជាមួយម៉ែហ្នឹង!

ក៖ អូ៎!

ខ៖ ធ្លាប់តែមានតែរឿងចឹង។

ក៖ អូ៎!

ខ៖ ដើរដូរដើរលក់ហ្នឹង!

ក៖ បាទមីងបាទអើឪពុកគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅមីងទេ?

ខ៖ ទេអត់ប្រាប់ផង។

ក៖ អូ៎ម្ដាយក៏អត់ដែរនិយាយអីដែរណោះមីង?

ខ៖ អត់ដែរនិយាយអីផង។

ក៖ អូ៎ចុះអើយាយតាខាងឪពុកមីងស្គាល់ឈ្មោះគាត់ទេ?

ខ៖ អត់ស្គាល់ផងភ្លេចអស់ហើយខ្ញុំភ្លេចឈ្មោះអីៗពិបាកចាំហាស!

ក៖ អូ៎យាយតាខាងឪពុកយាយតាខាងម្ដាយក៏អត់ចាំដែរ?

ខ៖ ខាងម្ដាយចាំឈ្មោះឡឪពុកគាត់ឈ្មោះសឿគាត់ឈ្មោះបានរួចម៉ែគាត់ឈ្មោះយាយមុត។

ក៖ តាសឿយាយមុត?

ខ៖ ចា៎!

ក៖ យាយមុតអូបាទមីងចុះអើមីងមករស់នៅគៀនជ្រៃអើរស់នៅទួលរកាហ្នឹងអស់រយះពេលប៉ុន្មានឆ្នាំហើយមីង?

ខ៖ សាមសិបបីឆ្នាំតាំងពីមានប្តីមកនៅហ្នឹងរហូត។

ក៖ អូ៎ចុះពីមុនហ្នឹងមីងនៅណា?

ខ៖ នៅខាងភូមិគៀនជ្រៃ។

ក៖ អូ៎ចឹងមីងនៅហ្នឹងទើបមកនៅខាងប្តីហោស?

ខ៖ ប្តីសាមសិបបីឆ្នាំហើយ!

ក៖ បាទមីងបាទចុះមីងមានដូចជាបងប្អូនកូនចៅណាដែរមីងគិតថាទៅរស់នៅក្រៅប្រទេសមានទេមីង?

ខ៖ អត់មានផង។

ក៖ អត់មានទេណោះមីង?

ខ៖ អត់មានទេ។

ក៖ អូ៎បាទមីងចុះអើទៅរស់នៅខេត្តផ្សេងក៏អត់មានដែរ?

ខ៖ អត់មានទេនៅត្រឹមប្អូនពីរនាក់នៅត្រឹមភ្នំពេញពីរនាក់បងប្អូនស្រីហ្នឹងនៅខាងស្រុកភូមិហ្នឹង!

ក៖ អូ៎បាទមីងបាទចុះមីងគិតថាស្វាមីរបស់មីងឈ្មោះអីគេទៅមីង?

ខ៖ ឈ្មោះអ៊ុតមាន។

ក៖ អ៊ុតមាន?

ខ៖ ចុះសព្វថ្ងៃគាត់ធ្វើអីគេឥឡូវមីង?

ខ៖ គាត់ដើរធ្វើការធ្វើសំណង់អីចឹងទៅដើរធ្វើផ្ទះឈើផ្ទះ។

ក៖ អូ៎!

ខ៖ ធ្វើតិចតួចកំប៉េកកំប៉ុកហ្នឹង!

កៈ ឥឡូវគាត់នៅធ្វើចឹងទៅ?

ខៈ ចាំនៅធ្វើ។

កៈ ភាគច្រើន..?

ខៈ ជាទៅធ្វើទៅឈឺឈប់ទៅ។

កៈ អ៊ូភាគច្រើនគាត់ទៅធ្វើនៅណាមីង?

ខៈ មែមទៅធ្វើរាមណាឥឡូវនៅធ្វើនៅជិតៗហ្នឹងដែរ។

កៈ អ៊ូបាទមីងបានចុះអើមីងមានកូនប៉ុន្មាននាក់មីង?

ខៈ ខ្ញុំកូនបួន។

កៈ កូនបួន?

ខៈ ចាំ!

កៈ កូននៅណាខ្លះទៅមីង?

ខៈ កូនគេមានប្ដីនៅកំពង់សោម នៅក្រូចឆ្មា។

កៈ អ៊ូកូនទីមួយឈ្មោះអីគេហើយនៅណាទៅមីង?

ខៈ នៅជាមួយរាល់ថ្ងៃហ្នឹងឈ្មោះរី។

កៈ អ៊ូគាត់មានកូនគាត់ទៀត?

ខៈ អត់មានទេនៅមិនទាន់មានប្រពន្ធទេអាយុសាមពីរហើយ!

កៈ អ៊ូកូនទីមួយហោស?

ខៈ កូនទីមួយកូនបងគេ។

កៈ រួចចុះកូនទីពីរ?

ខ៖ កូនទីពីរមានប្រពន្ធដែរហើយ!

ក៖ នៅណា?

ខ៖ នៅជិតហ្នឹងដែរ។

ក៖ អ៊ំពួកគាត់ធ្វើអីគេមីង?

ខ៖ ធ្វើស្រែចំការតិចតួចហ្នឹងដើរធ្វើការធ្វើងារអោយគេគ្មានមុខរបរអីធំដុំទេក្មួយអើយ!

ក៖ អ៊ំបាទមីងបាទរួចចុះអើទីបីមីង?

ខ៖ ទីបីគេមានប្តីទៅនៅក្រូចឆ្មាទៅនៅខាងប្តីគេ។

ក៖ អ៊ំគាត់មានកូនណេះមីង?

ខ៖ កូនពីរ។

ក៖ អ៊ំបាទមីងបាទចុះពៅគេ?

ខ៖ ពៅគេកូនមួយ។

ក៖ ទៅនៅកំពង់សោម?

ខ៖ ចា៎!

ក៖ គាត់ធ្វើអីគេនៅណុង?

ខ៖ ធ្វើនៅខាងនេះចិតបន្លែអោយចិនអនឡាញគេធ្វើអនឡាញចិន។

ក៖ អ៊ំបាទមីងចឹងមីងការអស់ប៉ុន្មានឆ្នាំហើយមីង?

ខ៖ ខ្ញុំខ្លួនឯងហ្នឹងហោស?

ក៖ បាទ!

ខ៖ សាមសិបបីឆ្នាំ។

កៈ ដោយសារអើមីងការហើយមីងអត់ទាន់ទំនេរពោះអើមីងអត់ទំនេរពោះទេមីងយកកូន?

ខៈ ទំនេរបានមួយខែអ៊ូបានមួយឆ្នាំ។

កៈ មួយឆ្នាំហោសមីង?

ខៈ ចាំកូនអាយុសាមពីរ។

កៈ អ៊ូបាទមីងបាទចុះមីងគិតថាពេលដែរមីងរៀបអាពាហ៍ពិពាហ៍ហ្នឹងដូចជាអើមីងចិត្តចង់រៀបដោយខ្លួនឯងរឺមួយក៏ឪពុកម្ដាយអ្នករៀបចំអោយយើងពេលណុងមីង?

ខៈ ឪពុកម្ដាយមានដឹងអីទេដឹងតែថាការតែម៉ងហ្នឹង!

កៈ អ៊ូ!

ខៈ កាលណុង។

កៈ បាទមីងបាទអើមីងការហ្នឹងនៅឆ្នាំណាមីងកៅប៉ុន្មាន?

ខៈ ប៉ែត្រជាងហើយហោស?

កៈ ប៉ែត្រប្រាំបួន?

ខៈ អត់ទេលឺថាប៉ែត្របួនអីទេហីគិតមើល។

កៈ គិតមើលអស់សាមសិបឆ្នាំជាងសាមបីឆ្នាំប៉ែត្រប្រាំពីរ។

ខៈ ប៉ែត្រប្រាំពីរហោស?

កៈ បាទមីង!

ខៈ ប៉ែត្រប្រាំពីរហោស?

កៈ បាទមីងបាទចុះមីងគិតថាចឹងកាលពីជំនាន់មីងការហ្នឹងមានជាថ្លៃទឹកដោះថ្លៃជំនូនអត់មីង?

ខៈ មានបង្គាប់កាលណុងប្រាំមួយពាន់លុយយើងហ្នឹងហាសអាប្រាំមួយពាន់លុយយើងចាយរាល់ថ្ងៃហ្នឹងហាស!

កៈ អ៊ូប៉ុន្តែកាល..?

ខៈ កាលណុងលុយថ្លៃ។

កៈ ជំនាន់ណុងលុយរៀងថ្លៃណោះមីងណោះ?

ខៈ ចាំធ្វើបានប្រាំមួយពាន់ហ្នឹងធ្វើបានមួយល្មមហ្នឹង!

កៈ អ៊ូបាទមីងបាទលក្ខណៈប្រាំមួយពាន់លុយច្រើនដែរណោះមីងណោះ?

ខៈ ចាំលុយច្រើនធ្វើបានធ្វើបានគ្រប់គ្រាន់។

កៈ អ៊ូ!

ខៈ អត់ខ្វះទេ។

កៈ បាទមីងបាទចុះមីងគិតថានៅពេលដែរមីងរៀបអាពាហ៍ពិពាហ៍ជមួយស្វាមីរបស់មីងហ្នឹងដូចជាមីងស្គាល់គ្នាពីមុនហើយនៅ?

ខៈ អត់ស្គាល់ទេមកលក់នុំបញ្ចុះទូលនុំបញ្ចុះតាមហ្នឹងគេស្គាល់ដើរលក់។

កៈ អ៊ូគេចូលដណ្ដឹងហោស?

ខៈ ចាំ!

កៈ អ៊ូចឹងយើងអត់ធ្លាប់មានអនុស្សាវរីយ៍ដើរលេងអីជាមួយគ្នាពីមុនអត់ទេ?

ខៈ អត់ទេអត់ទេ។

កៈ មែនដូចក្មេងឥឡូវទេណោះមីង?

ខៈ រកតែកង់ជិះគ្មានពីណាដើរលេងអីណាស្គាល់តែដើរ ដើរស្មើរជើង។

កៈ បាទមីងបាទចុះមីងគិតថាអើភាសាខ្មែរមីងធ្លាប់រៀនបានប៉ុណ្ណាមីង?

ខៈ រៀនបានត្រឹមថ្នាក់ទីបួនហ្នឹងខ្ញុំហោស!

ក៖ ជំនាន់ណុងណោះមីង?

ខ៖ ចាំបើអាទូលតែលក់ពេកទៅរៀនលែងចូល។

ក៖ អូ៎!

ខ៖ បើព្រលឹមបាត់ព្រលប់ដល់ម៉ោងមួយអីមិនទាន់ផ្ទះផងដាច់បាយក្រហាយទឹកដាច់ពីអាព
តមកវេទនាដែរ។

ក៖ បាទមីងបាទ!

ខ៖ ស្គាល់ទូលហើយហ្នឹងលក់បានរៀនទៅដល់ណាទេ។

ក៖ ចឹង..?

ខ៖ ម៉ែឪយើងក្រ។

ក៖ បាទមីងត្រូវចុះមីងគិតថាអើមីងមានចេះភាសាអីក្រៅពីភាសាខ្មែរទេដូចភាសាបារាំងភាសា
អីអត់?

ខ៖ អត់ចេះទេ។

ក៖ កាលណុងមីងអត់បានរៀនទេណោះ?

ខ៖ អត់បានទេរៀនបានតិចមួយហ្នឹង!

ក៖ អូ៎បាទមីងចុះកាលមីងរៀនខ្មែរហ្នឹងមីងរៀននៅណាមីងកាលណុង?

ខ៖ រៀននៅសាលាមុនដំបូងសាលាដើមអំពិល។

ក៖ អូ៎!

ខ៖ ទៅពីសាលាដើមអំពិលទៅទៅរៀនសាលាវត្តក្រៅ។

ក៖ អូ៎!

ខ៖ ទៅវត្តក្រៅទៅបានបង្កើតសាលានៅអីនៅអ្នកតាល័ក្ខអើអ្នកតាល័ក្ខហ្នឹងហើយនេះព្រំប្រទល់ភូមិថ្មីហ្នឹង!

ក៖ បាទមីងបាទ!

ខ៖ ដល់ណុងឈប់រៀនបាត់ហើយ!

ក៖ អូ៎!

ខ៖ រៀនសាលាល្ងៀកហ្នឹងហាស!

ក៖ បាទមីងចុះមីងគិតថាចឹងដូចជាកាលមីងរៀនហ្នឹងមីងធ្លាប់មានមិត្តភក្តិស្និទ្ធស្នាលដែរធំធាត់មកជាមួយគ្នាអត់មីង?

ខ៖ មានតើ!

ក៖ មានដែរណេះមីង?

ខ៖ ចា៎!

ក៖ ប៉ុន្តែភាគច្រើនពួកគាត់នៅណាមីង?

ខ៖ នៅខាងគៀនជ្រៃហ្នឹងហាស!

ក៖ អូ៎ប៉ុន្តែយើងឥឡូវយើងនៅតែទាក់ទងគ្នាតើណេះមីងណេះ?

ខ៖ ធម្មតាឃើញហៅគ្នាធម្មតាហ្នឹង!

ក៖ អូ៎!

ខ៖ នៅរាប់អានគ្នារហូត។

ក៖ បាទមីងបាទមីងធ្លាប់មានអនុស្សាវរីយ៍រីមួយក៏មានរឿងអីចងចាំជាមួយមិត្តភក្តិកាលមីងនៅរៀនជាមួយគាត់អត់?

ខ៖ អត់មានមិត្តភក្តិមានតែល្អៗគេមានទៅគេហៅអោយយើងហូបចុកជាមួយគ្នាទៅយើងអត់មានហាស!

ក៖ បាទមីង!

ខ៖ គេរៀងគ្រាន់បើជាងយើង។

ក៖ បាទមីងបាទ!

ខ៖ ពេលណាយើងគ្មានលុយទៅគេទិញអីយកមកអោយយើងហ្នឹងហូបចុកជាមួយគេទៅ។

ក៖ អូ៎!

ខ៖ គេសុទ្ធតែល្អៗដែរគេចិត្តល្អ។

ក៖ បាទមីងបាទ!

ខ៖ ហ្នឹងហើយមានអាក្រក់ទេ។

ក៖ ចឹងចុះមីងគិតថាចឹងស្រែចំការមីងធ្លាប់ធ្វើណោះមីងណោះ?

ខ៖ អស់ហើយ!

ក៖ អូ៎ភាគច្រើននៅស្រែមីងធ្វើអីគេទៅមីង?

ខ៖ ស្ទូងដកហ្នឹង!

ក៖ អើច្រូតកាត់..?

ខ៖ ច្រូតកាត់ហ្នឹង!

ក៖ ភ្ជួររាស់មីងចេះអត់?

ខ៖ អត់ទេៗ។

ក៖ អត់ចេះទេណោះមីង?

ខ៖ គ្រាន់តែថាច្រូតកាត់ស្ទូងដកហ្នឹង!

ក៖ ប៉ុន្តែឥឡូវគេលែងស្ទូងលែងអីហើយណោះមីង?

ខ៖ លែងស្ទូងហើយឥឡូវគេព្រុះយកហើយ!

ក៖ គេព្រុះយកព្រុះលឿន?

ខ៖ គេមានម៉ាស៊ីនមានអីទៅគេព្រុះឥឡូវគេរីកចំរើនទៅ។

ក៖ អូ៎!

ខ៖ គេឥឡូវគេលែងសូវប្រើដៃរគេប្រើទន្លេថង។

ក៖ អូ៎បាទនិយាយរួមឥឡូវអោយតែលុយមីងណោះជួលគេទាំងអស់?

ខ៖ ចាំគេជួលទាំងអស់ឥឡូវហោស!

ក៖ អូ៎អត់ពិបាកដូចមុនទេណោះមីង?

ខ៖ អត់ពិបាកដូចមុនជំនាន់ខ្ញុំទេខ្ញុំជំនាន់ខ្ញុំប្រើតែកំលាំងទាំងអស់។

ក៖ អូ៎បាទមីងបាទចុះមីងគិតថាចំការចំការមីងធ្លាប់ធ្វើអត់មីង?

ខ៖ ចំការគេដាំថ្នាំគេដាំប៉ិគក់ដាំអីហ្នឹង!

ក៖ អូ៎!

ខ៖ មិនដែរទៅធ្វើទេប៉ុននៅចំការជិតហ្នឹងគេដាំចឹងខ្ញុំធ្លាប់តែធ្វើស្រែចំការ។

ក៖ អូ៎បាទមីង!

ខ៖ ធ្វើស្រែដកស្ទូងធ្វើស្រែធ្វើស្រូវ។

ក៖ បាទមីងបាទចុះមីងគិតថាលក់ដូរមីងធ្លាប់តែលក់នុំបញ្ចុះទេណោះមីងណោះ?

ខ៖ ធ្លាប់ចេញពីលក់នុំបញ្ចុះមកបានជិះកង់ជិះអីទៅលក់ត្រីលក់អីនៅផ្សារបឹងកុកដៃរ។

កៈ អ៊ំ!

ខៈ ទើបខានលក់ប្រហែលបួនដប់ឆ្នាំហ្នឹង!

កៈ បាទមីងបាទ!

ខៈ ពីមុនខ្ញុំទៅលក់នៅផ្សារ។

កៈ អ៊ំជិះទៅដល់បឹងកុកហោស?

ខៈ ចាំ!

កៈ ឆ្ងាយហាសណោះមីង?

ខៈ ជិះទៅលក់ផ្អកត្រសក់ផ្អកអីហ្នឹងហាស!

កៈ បាទមីងបាទ!

ខៈ ជិះកង់ទៅក្រោកម៉ោងបីម៉ោងបួនភ្លឺហ្នឹង!

កៈ ប៉ុន្តែឆ្ងាយហាសណោះមីងណោះ?

ខៈ ទៅលក់ពោតលក់អីហ្នឹងចេះតែលក់ហើយរឿងលក់ហោសតិចតួចចេះតែលក់រហូតណុង។

កៈ បាទ!

ខៈ តាំងពីទូលពីក្បាលរហូតដល់ជិះកង់។

កៈ បាទមីងបាទចុះអើមីងគិតថាមីងធ្លាប់ចិញ្ចឹមសត្វពីមុនទេមីងដូចមាន់ ទា ជ្រូក គោ ក្របី ត្រី អីចឹងហាសណាស់?

ខៈ អត់ដែរចិញ្ចឹមទេត្រីដែរចិញ្ចឹមជ្រូកចិញ្ចឹមមួយគូរៗ។

កៈ អ៊ំមាន់ទេក៏អត់ដែលដែរ?

ខៈ មានមាន់ទាគ្រាន់តែចិញ្ចឹមនៅក្នុងគ្រួសារតិចតួចហ្នឹងហាសអត់មានអាជីវកម្មធំហ្នឹងគេទេ។

កៈ អុំ!

ខៈ អោយតែចិញ្ចឹមប្អូនដប់ម្ភៃហ្នឹង!

កៈ បាទមីងបាទចុះមីងគិតថាអើដូចជាកាលពីក្មេងរហូតដល់ឥឡូវការងារអីគេខ្លះដែរមីងធ្លាប់ធ្វើទៅមីង?

ខៈ ធ្លាប់ធ្វើមានតែទូលលក់ហ្នឹងហើយច្រូតកាត់ហ្នឹងហើយលក់ហ្នឹងលក់នៅផ្សារនៅស្រែដើរលក់។

កៈ អុំបាទ!

ខៈ ធ្លាប់ធ្វើតែប៉ុណ្ណឹង!

កៈ បាទមីងបាទចុះអើកាលពីក្មេងមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេខ្លះទៅកាលមីងនៅជាមួយឪពុកម្តាយដល់ពេលឥឡូវគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេខ្លះទៅមីង?

ខៈ ផ្លាស់ឥឡូវផ្លាស់គ្រាន់ថាវារៀងស្រួលតិចចាស់ទៅហ្នឹងវាមិនអត់ប៉ុន្មាន។

កៈ អុំបាទមីងបាទ!

ខៈ ចាំនៅពីតូចណុងវាយ៉ាប់។

កៈ អុំបាទមីង!

ខៈ ចាំ!

កៈ កាលនៅតូចពិបាកជាងឥឡូវណោះមីងណោះ?

ខៈ ពិបាកពិបាកខ្លាំងហាស!

កៈ អុំចុះមីងគិតថាអើទាំងជីវភាពសុខភាពមីងឥឡូវម៉េចដែរមីង?

ខៈ សុខភាពមិនសូវជាទេជីវភាពក៏ថាម៉ាគ្រប់គ្រាន់ចុះឥឡូវហោស!

កៈ អុំ!

ខ៖ វាគ្រាន់តែបានវាមិនមានទេណាស់វាម៉ាគ្រប់ម៉ាគ្រាន់។

ក៖ បាទមីងបាទ!

ខ៖ ប៉ុនសុខភាពនៅតែមិនសូវជាទេតិចឈឺនេះតិចឈឺនោះហើយនៅរាល់ថ្ងៃហ្នឹងហោស!

ក៖ ឥឡូវពិបាកដែរណេះមីងណេះ?

ខ៖ ចាំពិបាកសុខភាពហ្នឹងម៉ង។

ក៖ អូ៎បាទមីង!

ខ៖ ព្រោះវាបាក់ពីក្មេងទៅហ្នឹងហាស!

ក៖ បាទមីង!

ខ៖ រហូតឈឺក្បាលម៉ងខ្លាំងទៅ។

ក៖ អូ៎បាទមីងបាទចុះអើមីងគិតថាម្ហូបអីដែរមីងចូលចិត្តហូបមីងម្ហូបដែរមីង..?

ខ៖ សាច់មិនសូវចូលចិត្តទេខ្ញុំចូលចិត្តតែត្រីទេ។

ក៖ អូ៎ចឹងហោសមីង?

ខ៖ ចាំ!

ក៖ អូ៎ចុះមីងកាលពីក្មេងមីងគិតថាមីងធ្លាប់លេងល្បែងប្រជាប្រិយ៍អីទេមីងលក្ខណៈដូចបោះអង្គុញ ចោលឈូង លាក់កន្សែង ទាញព្រាត់អីចឹងហាសណាស់?

ខ៖ ពីក្មេងមកហោស?

ក៖ បាទមីងបាទ!

ខ៖ ដែលដែរទៅលេងនៅវត្តក្នុងហ្នឹងគេលេងចោលឈូងចោលហ្នឹងគេទៅ គេបោះអង្គុញបោះហ្នឹងគេទៅគេទាញព្រាត់ទាញហ្នឹងគេទៅកាលពីក្មេងៗហោស!

ក៖ បាទមីងបាទ!

ខ៖ អាយុដប់ប្រាំមួយដប់ប្រាំពីរ។

ក៖ អ៊ូត្រូវមីងចុះមីងគិតថាអើទាក់ទងពីច្រៀងមីងចូលចិត្តទេមីង?

ខ៖ អត់ចេះផង។

ក៖ អត់ចេះច្រៀងទេណោះមីង?

ខ៖ ចាំអត់ចេះទេ។

ក៖ ចុះអើរាំរែកអីក៏អត់ចេះដែរ?

ខ៖ ចេះចេះរាំរែកហ្នឹងគេរាំហ្នឹងគេលេងអីលេងហ្នឹងគេទៅ។

ក៖ អ៊ូ!

ខ៖ កាលពីក្មេងមកហោស!

ក៖ បាទមីងបាទរួចចុះទាក់ទងពីអើល្ខោនយីកេអាយ៉ៃមីងចូលចិត្តទេ?

ខ៖ ចូលចិត្តតើ!

ក៖ អ៊ូ!

ខ៖ ចូលចិត្តទាំងអស់រឿងគេច្រៀងអីហ្នឹងដល់ចំណាស់ហ្នឹងហើយក៏នៅតែចង់ស្តាប់ចង់ឃើញចង់មើលដែរ។

ក៖ អ៊ូ!

ខ៖ ត្បិតអត់នេះទេ។

ក៖ បាទមីងបាទចុះមីងគិតថាអើដូចចឹងជាមីងមាននរណាគេមួយនៅក្នុងក្រុមគ្រួសារចេះលេងឧបករណ៍ភ្លេងទេមីង?

ខ៖ អត់មានទេក្មួយ។

ក៖ ភ្លេងខ្មែរភ្លេងសៀមអីក៏អត់ចេះដែរ?

ខ៖ អត់មានទេអត់មានសោះ។

ក៖ អ៊ុំបាទមីងបាទផ្ទះរបស់មីងមានលក្ខណៈបែបណាមីងតាំងពីក្មេងរហូតមកដល់ឥឡូវ?

ខ៖ ផ្ទះពីក្មេងផ្ទះតូចត្រឹមជង្គង់។

ក៖ អ៊ុំ!

ខ៖ ប្រកស្បូវ។

ក៖ អ៊ុំបាទមីង!

ខ៖ បន្ទាប់ពីស្បូវមកគ្រើសតិចទៅប្រហែលប្រាំប្រាំមួយអីចឹងទៅប្រកដែក។

ក៖ អ៊ុំបាទមីងបាទ!

ខ៖ ចាំពីក្មេងមកអត់មានផ្ទះធំនៅទេ។

ក៖ អ៊ុំរួចចុះកាលណុងនៅណាមីង?

ខ៖ នៅកាលនៅជាមួយម៉ែឪនៅណោះភូមិគៀនជ្រៃ។

ក៖ អ៊ុំប៉ុន្តែរហូតមកដល់ឥឡូវបានផ្ទះប៉ុណ្ណឹងណោះមីងណោះ?

ខ៖ ចាំ!

ក៖ ហ្នឹងផ្ទះមីងណោះមីងណោះ?

ខ៖ នោះផ្ទះនោះផ្ទះតញ្ញាបមកមុខដំបូល។

ក៖ អ៊ុំនោះហោស?

ខ៖ ចាំផ្ទះណុង។

ក៖ អ៊ុំបាទមីងចុះអើផ្ទះណុងយើងសាងសងជាមួយកូនចៅយើងណោះមីងណោះ?

ខ៖ ចាំជាមួយប្ដីប្រពន្ធ។

កៈ អ៊ំ!

ខៈ កូនចៅ។

កៈ បាទមីងបាទប៉ុន្តែអើដូចជាប្ដីរបស់មីងរឺមួយកូនចៅចេះធ្វើផ្ទះអត់មីង?

ខៈ អត់ចេះផងប្ដីចេះធ្វើផ្ទះបើកូនចៅអត់ចេះទេ។

កៈ ចឹងហោសមីងហោស?

ខៈ ចាំ!

កៈ អ៊ំបាទមីងបាទចុះមីងគិតថាដូចជាឪពុកម្ដាយមីងធ្លាប់បង្រៀនពីជំនាញអីផ្សេងទៅមីងកាលគាត់នៅរស់ហាសគាត់ដូចជាវេញវល្លិ៍ កូរស្ករធ្វើកន្ទេល ធ្វើល្អីធ្វើអីផ្សេងៗដូចត្បាញអីធ្លាប់បង្រៀនអត់?

ខៈ គាត់អត់ដែរបង្រៀនផង។

កៈ គាត់បង្រៀនតែធ្វើនំុបញ្ចុះតើហី?

ខៈ ចាំធ្វើនំុបញ្ចុះធ្វើអីហ្នឹង!

កៈ អ៊ំ..!

ខៈ រួចបង្រៀនវេចអន្សមវេចអីចឹងទៅ។

កៈ អ៊ំកាលមីងធ្វើនំុបញ្ចុះហ្នឹងគេធ្វើម៉េចទៅមីង?

ខៈ កាលណុងអត់មានម៉ាស៊ីនដូចឥឡូវទេកិនត្រាំអង្ករដូចថាស្អែកត្រូវធ្វើថ្ងៃត្រូវធ្វើដល់មួយគីឡូអង្ករយើងលាងអង្ករត្រាំដល់ពេលព្រលឹមឡើងយើងកិន កិនរួចទៅបង្ហាប់វាមួយយប់ទៅនេះអោយស្ងួតក្រវៅវាអោយស្ងួតដាក់ស្មោរហ្នឹង ស្មោរអោយឆ្អិនប្រវែងនេះទៅម៉ាក្រវៅប៉ុណ្ណឹងហាស!

កៈ បាទមីង!

ខៈ អោយឆ្អិនប្រវែងហ្នឹងទៅយើងលើកយកទៅជាន់។

កៈ អ៊ូ!

ខៈ ជាន់លើត្បាលហាស!

កៈ បាទមីងបាទ!

ខៈ ដែរឃើញអត់ជាន់ចេះដែរ។

កៈ ធ្លាប់?

ខៈ ហ្នឹងហើយៗជាន់ហ្នឹងត្បាលហ្នឹងរួចបានយកមករួយ។

កៈ អ៊ូ!

ខៈ ដាំទឹកដាក់ឆ្នាំងទៅបែនទៅយើងអង្គុយពីលើរួយអង្គុយលើបែនដាក់ឬស្សីហ្នឹងហាស!

កៈ បាទមីង!

ខៈ វីចេញមក។

កៈ បាទ!

ខៈធ្វើផ្ទាល់រាល់ថ្ងៃ។

កៈ កាលជំនាន់មុនណោះមីងណោះ?

ខៈ ហ្នឹងហើយជំនាន់មុនខ្ញុំធ្វើហ្នឹងហាស!

កៈ បាទមីងបាទ!

ខៈ ជំនាន់យាយជំនាន់ខ្ញុំហ្នឹង!

កៈ ប៉ុន្តែដល់ពេលឥឡូវស្រួលណោះមីងណោះ?

ខៈ ឥឡូវគេស្រួលឥឡូវគេធ្វើម៉ាស៊ីនទាំងអស់។

កៈ អ៊ូ!

ខ៖ គេលាងអង្ករួចគេរួចហ្នឹងគេធ្វើបានភ្លាមៗគេគ្មានបង្អាប់ទេឥឡូវហោសអត់ម៉េ្យាដូចមុនទេ។

ក៖ ជំនាន់យើងយើងត្រូវការបង្អាប់ម៉េ្យាសិន?

ខ៖ បើគ្រាន់តែកិនស្នាហ្នឹងដល់ព្រលប់ដប់គីឡូកិនល្មមរួចយប់ហើយ!

ក៖ អ៊ូ!

ខ៖ យើងធ្វើណាចេញមាត់យើងសង្កត់ទៀតហោសចងសង្កត់អោយស្រស់ទឹក។

ក៖ បាទមីង!

ខ៖ ចាំ!

ក៖ ចឹងភាគច្រើនបើធ្វើយើងចំណាយរយះពេលរយះពេលប៉ុន្មានថ្ងៃទៅមីងធ្វើ?

ខ៖ ពីរថ្ងៃ។

ក៖ ល្មមតែធ្វើហើយបានលក់?

ខ៖ ចាំ!

ក៖ អ៊ូចាយពេលច្រើនហាសណោះមីង?

ខ៖ ចាំពេលច្រើនហាសមិនដឹងរកអីចេះតែរកចេះតែធ្វើទៅ។

ក៖ អ៊ូជាពិសេសអើប្អូនដប់គីឡូអីចុះយើងលក់យើងចំណេញបានប៉ុន្មានទៅបើទៅលក់ម្តង?

ខ៖ កាលណុងដូរជាស្រូវបានប្អូនដប់គីឡូអង្ករអីចឹងទៅ។

ក៖ អ៊ូ!

ខ៖ ដូររួចទៅកិនអង្ករទៅដូចថាធ្វើអស់ដប់គីឡូយើងបានម្ភៃគីឡូហ្នឹងយើងបានប្អូនដប់គីឡូអង្ករហ្នឹងហាស!

ក៖ បាទមីងបាទអ៊ូអត់សូវបានច្រើនដែរណោះមីងណោះ?

ខ៖ បានប៉ុណ្ណឹងគ្មានច្រើនទេច្រើនហើយណុងហោស!

ក៖ អូ៎បាទមីងបាទចុះមីងគិតថាមីងអាចប្រាប់ខ្ញុំពីការលំបាកបានទេមីងតាំងពីក្មេងរហូតមកដល់ឥឡូវដូចជាអើជំនាន់លុនណុលប៉ុលពតដែរមីងទាន់ចឹងហាសណាស់?

ខ៖ ជំនាន់ប៉ុលពតដឹងក្ដីឡើងឆ្នាំហ្នឹងទៅគេគេអត់អោយយើងដេកផ្ទះជាមួយម៉ែឪគេអោយដេកនៅកន្លែងគេធ្វើការហ្នឹងនៅរៀនផងវែកដីផង។

ក៖ អូ៎បាទ!

ខ៖ ព្រលឹមឡើងវែកដី។

ក៖ បាទមីង!

ខ៖ ថ្ងៃត្រង់ស៊ីបាយក្នុងរោងបាយណុងនៅផ្ទះគេណុងទៅនៅសាលាគេណុងទៅ។

ក៖ បាទមីងបាទរួចចុះអើមីងកើតទាន់ជំនាន់លុនណុលទេណោះមីងណោះ?

ខ៖ អត់ទេត្រឹមប៉ុលពត។

ក៖ ប៉ុលពត?

ខ៖ ចា៎!

ក៖ អូ៎ប៉ុន្តែមីងគិតថាអើជំនាន់ហ្នឹងដូចជាមីងគេជំលាសទៅណាដំបូង?

ខ៖ គេជំលាសទៅខាងគគរគគរនេះគគរកោះរកានេះ។

ក៖ អូ៎អាហ្នឹងយើងទៅដំបូងយើងធ្វើអីគេ?

ខ៖ ទៅដំបូងហ្នឹងគេអោយទៅបែកគ្នាគេអោយទៅវែកដីតែម៉ង។

ក៖ វែកដីហោសមីងហោស?

ខ៖ ចា៎វែកដីអូសបង្គី។

ក៖ អូ៎!

ខ៖ ខ្ញុំភ្លោះពីរនាក់ប្អូនពីរនាក់បងណុងប៉ុនគ្នាហ្នឹង!

ក៖ បាទមីង!

ខ៖ វែកដីគេចងបង្គីវែក។

ក៖ ទៅជាមួយគ្នាហោស?

ខ៖ ចាំទៅទាំងអស់គ្នាគេអោយបំបែកទៅណុងវែកទាំងអស់គ្នាណុង។

ក៖ អូ៎ចឹងមានន័យថាបងប្អូនមីងទីណុងទាំងអស់គ្នាម៉ង?

ខ៖ ទៅទាំងម៉ែទាំងអីទាំងអស់ទាំងបងប្អូនទាំងអស់។

ក៖ ចេញគេជំលាសចេញជាគ្រួសារម៉ងហោស?

ខ៖ ចាំទៅណុងប្អូនប្រុសពីរណុងវានៅតូចៗប៉ុនៗនេះអាយុបួនឆ្នាំប្រាំឆ្នាំអាប្រុសពីរណុងហោស!

ក៖ អូ៎!

ខ៖ ហើយខ្ញុំពីរនាក់បងប្អូនណុងវាធំ។

ក៖ អូ៎បាទមីង!

ខ៖ ធំអាយុដប់ឆ្នាំណុងវែកដី។

ក៖ ចុះអើមីងគិតថាចឹងអើមីងគេអោយនៅជាមកងកុមារណោះមីងណោះ?

ខ៖ ចាំកុមារ។

ក៖ ចុះអើវែកដីចឹងយើងមានកំលាំងណាមីង?

ខ៖ មានកំលាំងណាអូសឡាកឡើតៗដាក់ដីពីរបីបង្គីវែកមិនចង់រួចគេបង្ខំហើយចេះតែទៅទៅ។

ក៖ អូ៎!

ខ៖ ឡាកឡើតៗហោសចាំជាប់ម៉ង។

ក៖ អ៎ូចុះរបបអាហារយើងម៉េចទៅមីង?

ខ៖ របបអាហារហោស!

ក៖ យើងហូបបបររឺយើងហូបបាយមីង?

ខ៖ បបរមួយខ្ទះណុងដួសមកឃើញកាក់ហ្នឹងពីរស្លាបព្រាមួយស្លាបព្រា។

ក៖ អ៎ូ!

ខ៖ ទឹកហ្នឹងហុតតែទឹកហ្នឹងបបរណុងមួយស្លាប់ព្រាពីរស្លាបព្រាណុងកាក់ណុងហាស!

ក៖ បាទមីងបាទ!

ខ៖ មានលាយគ្រាប់ពោតរីកប៉ុនៗកូនដៃមេដៃគ្រាប់ពោតក្រហមគ្រាប់ពោតសលាយគ្នាទៀត។

ក៖ អ៎ូបាទមីង!

ខ៖ ចេះតែច្រូកទៅអោយយើងស៊ីហ្នឹងមានអីស៊ី។

ក៖ អ៎ូរួចចុះអើដូចជាពេលហ្នឹងយើងឈឺអីម៉េចទៅមីង?

ខ៖ យើងឈឺកាលណុងមានពេទ្យគេមើលឈឺកាលណុងអត់មានពោគអីទេមានតែអ្នកមានតែហែមព្រោះគ្មានអំបិល។

ក៖ អ៎ូ!

ខ៖ អោយស៊ីបបរណុងមិនសូវមានប្រៃណាបបរចេះតែហុតទៅមានអំបិលជាតិអំបិលណាជំងឺតែហើមទេទៅដល់ពេទ្យណុងគេអោយថ្នាំលេបថ្នាំសូន្យៗណុងថ្នាំស្អីគេទេចេះតែលេបៗទៅ។

ក៖ ចឹងហោសមីងអ៎ូចុះមីងគិតថាអើចឹងទាក់ទងពីការងារវិញគេអោយយើងធ្វើប៉ុន្មានម៉ោងទៅមីង?

ខ៖ ការងារម៉ោងប្រាំមួយទៅធ្វើហើយម៉ោងប្រាំបួនម៉ោងដប់បានគេអោយមកវិញ។

កះ អ៎ូ!

ខះ ម៉ោងប្រាំមួយចេញទៅហើយលើកចបមិនចង់រួចផងកាយដីហោស!

កះ បាទមីងបាទចុះមីងគិតថាចឹងអើមីងពីរនាក់ប្អូនរបស់មីងបន្ទាប់ណុងធ្វើការជាមួយគ្នា?

ខះ ចាំធ្វើការជាមួយគ្នា។

កះ រួចចុះប្អូនៗពីរនាក់ទៀត?

ខះ ប្អូនពីរនាក់ទៀតនៅប៉ុននេះម៉ែឪតូចៗណុងហាស!

កះ ប៉ុន្តែម៉ែឪគេអោយធ្វើអីគេមីង?

ខះ ម៉ែខ្ញុំគេអោយចិញ្ចឹមជ្រូក។

កះ អ៎ូ!

ខះ ចិញ្ចឹមជ្រូកចិញ្ចឹមមាន់។

កះ ប៉ុន្តែនៅណុងដែរ?

ខះ អើចិញ្ចឹមមាន់នៅជាមួយគ្នានៅឆ្ងាយនៅផ្ទះឆ្ងាយយើងគេអោយនៅឆ្ងាយណាស់ប៉ុនគាត់ចិញ្ចឹមជ្រូកចិញ្ចឹមមាន់។

កះ អ៎ូរួចចុះអើចឹងប៉ុន្មានថ្ងៃគេអោយយើងទៅលេងឪពុកម្តាយម្តងហោស?

ខះ ដូចរឿងអោយទៅគេមិនអោយទៅទេយើងលួចរត់ទៅ។

កះ អ៎ូ!

ខះ រត់ទៅៗដល់ពេលនេះរត់មកវិញមកជូនគេទៅតាមទៅអើក្មេងធ្វើម៉េច។

កះ ប៉ុន្តែគេអត់ថាអីទេមីងហោស?

ខះ គេថាដែរគេស្តីអោយគេដូចថាគំរាមថាអោយតែទៅមួយសារទៀតវ៉ៃចោលម៉ងថាចឹងហាស!

កៈ បាទមីង!

ខៈ នៅក្មេងណុងហាសថាអោយតែទៅផ្ទះម៉ែម្ដងទៀតអោយតែដឹងវ៉ៃចោលហើយ ប៉ុន្តែវាគ្រាន់តែថាវាមិនហ៊ានវ៉ៃដែរកាលណុង។

កៈ អ៎ូបាទមីងបាទ!

ខៈ តិចទៅៗហើយអើនៅតូចនឹកម៉ែតាមរកគាត់។

កៈ ប៉ុន្តែឪពុកម្ដាយអត់ដែរមករកយើងទេ?

ខៈ អត់ដែររកទេពយកគាត់រវល់ដាំនេះមើលជ្រូកជ្រូកកូនខ្ជីមាន់ផងរាប់រយហោស!

កៈ អ៎ូ!

ខៈ ពីណានៅមើលទៅ។

កៈ ពីរនាក់ប្ដីប្រពន្ធគាត់?

ខៈ ចាំនៅមើលទាំងអសគ្នាណុងឪពុកណុងពិការងាប់មួយចំហៀងខ្លួនណុងគេអោយដាក់បាយមាន់រួចម៉ែចិញ្ចឹមជ្រូក។

កៈ អ៎ូគាត់ក្រោកអត់រួចណោះ?

ខៈ គាត់ដើរបានមួយចំហៀងខ្លួនគាត់ងាប់មួយចំហៀងខ្លួនហាស!

កៈ បាទ!

ខៈ ដើររួចតែមួយចំហៀងទេ។

កៈ អ៎ូចឹងទៀត?

ខៈ ហ្នឹងហើយធ្វើការណុងហាស!

កៈ រួចដាក់ម៉េចកាន់ឈើច្រត់មួយចំហៀងទៅ?

ខៈ កាន់ឈើច្រត់ដើរខ្វាយៗហ្នឹងដៃយោលតាមនេះទៅមាននេះងាប់មួយចំហៀងខ្លួនណុង។

កៈ ដាក់បាយដាក់អីទៅ?

ខៈ បានមើលមាន់គេអោយមើលមាន់។

កៈ គ្នាច្រើនអត់មីង?

ខៈ ពីរបីគ្រួសារ។

កៈ អ៊ូបាទមីងចុះអើមីងគិតថាចឹងដូចជានៅពេលដែរយើងធ្វើចឹងទៅយើងឃ្លានយើងធ្វើម៉េចទៅមីងយើងមានលួចជីកដំឡូងជីកក្ដួចជីកអីហ្នឹងគេអត់ហាន់ត្រកួនហាន់អី?

ខៈ គាត់ដាក់បាយជ្រូកណុងហោស?

កៈ អត់ទេមីងហាសចង់និយាយថាយើងឃ្លានចឹងយើងមានត្រូវការជីកក្ដួចរឺមួយក៏ជីកដំឡូងអីដើម្បីទុកហូបអីលួចជីកហាសបងដូចថាយើងឃ្លានអីចឹង?

ខៈ ដែរជីកដំឡូងគល់ចេកអីនិយាយរួមទៅរត់ទៅម៉ែទៅណុម៉ែជំនាន់ណុងមនុស្សគេអោយស៊ីចាញ់សត្វទេ។

កៈ បាទមីងបាទ!

ខៈ សត្វគេស៊ីហូរហៀរជាងទៅស៊ីជាមួយជ្រូកណុងហាសគេស្ងោរគ្រាប់ពោតទាំងខ្ទះៗហ្នឹងរួចយើងនៅបានស៊ីហើយបងប្អូនណាទៅក៏បានស៊ីដែរម៉ោងប្រាំបីប្រាំបួនលឺតែឬស្សីផ្ទុះណុងម៉ែខ្ញុំហ្នឹងគាត់ដាក់ដាំគ្រាប់ពោតបីបួនខ្ទះរាយល្មមៗមាត់ចាបហ្នឹងហាស!

កៈ បាទមីង!

ខៈ ដល់ភ្នែកមើលស្ដាំមើលឆ្វេងហ្នឹងធ្មក់ក្រម៉ារៀងខ្លួនរត់មកវិញហើយយកមកស៊ី។

កៈ អើបាយជ្រូកហ្នឹងហោសមីង?

ខៈ បាយជ្រូកគេបបរអោយជ្រូកហ្នឹងហាស!

កៈ អើ!

ខៈ ប៉ុនគេស្ងោរគ្រាប់ពោតហ្នឹងហាសគេអត់លាយកន្ទកទេ។

កៈ អ៊ូ!

ខៈ ស្មោរគ្រាប់ពោតជាមួយកន្ទកជាមួយអីហ្នឹង!

កៈ បាទមីងបាទ!

ខៈ គេលាយជាមួយដើមចេករួចយើងចូកមកកន្លះៗប៉ុនៗនេះមកម្នាក់មួយកំប៉ុងទៅពីរកំប៉ុងទៅរើសយកគ្រាប់ៗពោតហ្នឹងស៊ីទៅ។

កៈ ចឹងហោសមីង?

ខៈ ចាំ!

កៈ អ៊ូ!

ខៈ ដូចចំនួនអង្គការគេថាអោយបបរតែបីខ្ទះគាត់លួចបបរដល់បួនខ្ទះអីចឹងហាស!

កៈ បាទ!

ខៈ គាត់ទុកចែកគេចែកឯងអ្នកទៅចំណាំតែបានស៊ីទៅរាល់តែថ្ងៃណុង។

កៈ អង្គការអត់ថាអីទេ?

ខៈ លួច។

កៈ និយាយថាអង្គការ..?

ខៈ អត់អោយគេឃើញ។

កៈ អង្គការអត់ដឹងទេ?

ខៈ អត់ដឹងទេលួចអត់អោយគេឃើញ។

កៈ ចុះគាត់លើសចំនួនក៏គេអត់ដឹងដែរ?

ខៈ ហ្នឹងហើយចាំបបរដូចថាគេអោយដាក់បីខ្ទះពេញៗរួចយើងធ្វើបួនខ្ទះទៅដាក់ម៉ាល្មមទៅណាស់។

កៈ បាទមីង!

ខៈ រួចដួសអោយគេរួចទៅដាក់ចូលត្រឹមបីខ្ទះវិញទៅល្មមបីខ្ទះហ្នឹងហើយ!

កៈ ចុះប៉ុន្តែចឹងគាត់ចេះតែធ្វើចឹងរាល់ថ្ងៃទៅ?

ខៈ ធ្វើចឹងរាល់ថ្ងៃដល់គេមកមើលក៏គេឃើញដែរប៉ុន្តែមានតែកន្លះបើដាក់ពេញទៅដាក់ឬស្សីទៅដុតភ្លើងខ្លាំងទៅវាពុះកញ្ជ្រួល។

កៈ បាទមីង!

ខៈ វាខ្សៀតទឹកចេញ។

កៈ អូ៎!

ខៈ ដល់ពេលដាក់កាចៗខ្ទះចឹងទៅវានេះអត់ខ្សៀតទឹកចេញហើយក៏ពោតវាឆាប់ឆ្អិនដែរ។

កៈ អូ៎ធ្វើចឹងហាសណេះមីងបានយើងហូប..?

ខៈ ចាំធ្វើចឹង។

កៈ ហូបបានឆ្អែតណេះ?

ខៈ ហ្នឹងហើយបានចែកអ្នកស្គាល់ៗគ្នាអត់មានទៅហោស!

កៈ បានយើង..?

ខៈ ភ្នែកសភ្នែកខ្មៅដាក់ជាយក្រម៉ាដាក់ជាយខោអាវចេញមកវិញ។

កៈ អូ៎បាទមីងបាទចឹងយើងបានអាហ្នឹងទប់បានឆ្អែត?

ខៈ បានអាហ្នឹងទប់ហ្នឹងហាសបានឆ្អែតខ្លះមិនឆ្អែតខ្លះ។

កៈ អូ៎ល្អមីងចុះមីងគិតថាចឹងអើនៅពេលដែរមីងមានចងចាំថាពេលណាដែរមីងធ្វើការពិបាកមីងគេជំលាសទៅតែមួយកន្លែងហ្នឹងទេណេះមីងណេះ?

ខៈ ជំលាសមួយកន្លែងហ្នឹង!

កៈ ប៉ុន្តែ..?

ខៈ ជំលាសមួយកន្លែងហ្នឹងដាច់តែម៉ង។

កៈ តែមីងគិតថាធ្វើអីគេដែរពិបាកជាងគេនៅជំនាន់ប៉ុលពត?

ខៈ ពិបាកហ្នឹងដើរគេជំលាសទៅហ្នឹងដើរទៅឆ្ងាយណាស់ដើរដេកតាមផ្លូវតាមផ្លូវហ្នឹងយប់ទីណាដេកទីណុង។

កៈ អ៎ូបាទមីងបាទ!

ខៈ បបរដាក់ហ្នឹងកំសៀវដាក់អីស៊ីហ្នឹងហាសជាងសត្វជាងធាតុទៀតជំនាន់ណុង។

កៈ អ៎ូបាទមីង!

ខៈ ដើរយំដើរស្រែអើបើវារុយជើងពេក។

កៈ បាទមីង!

ខៈ រួចឪពុកគាត់រួចម្ដាយប្អូនដល់ពីរអៀវមួយផងប៉មួយផងរួចយើងនៅតូចដែរហ្នឹងយំដើរយំស្រែរងេករងាកអើយពិបាកមែនទែនជំនាន់ណុង។

កៈ អ៎ូបាទមីងបាទ!

ខៈ ផុតពីណុងមកក៏ពិបាកដែរដាច់អាពតមកយើងក្រទូលល្អីហ្នឹងទិញស្ករពីស្រែមកយកទៅឌុបដល់កោះដល់មកវិញគ្មានស្បែកជើងពាក់អូសក្រម៉ា។

កៈ ចឹងហោសមីង?

ខៈ ដល់ពេលក្ដៅជើងហ្នឹង!

កៈ បាទមីង!

ខៈ ម៉ោងដប់មួយហ្នឹងខ្សាច់យើងវែងហាសពីដើមមកក្មួយឯងកើតមិនទាន់ទេ វែងណាស់ល្មមដើរដល់ទូកដរហ្នឹងម៉ោងដប់មួយដប់ពីរហ្នឹងយើងរត់ពីហ្នឹងទៅដល់ផ្លូវយើងឈរជាន់ក្រម៉ាមួយសារល្អីពាក់លើក្បាល។

កៈ ចឹងពងជើងងាប់ហើយចឹង?

ខៈ ពងហើយពងខ្លះអត់ខ្លះមើលតែនេះទៅដោះពីល្អីពីក្បាលមកដាក់លើខ្សាច់ហ្នឹងជាន់នៅក្នុងល្អីសិន។

កៈ រួចចុះ..?

ខៈ មើលតែត្រជាក់ណុងទៅទៀតហើយយកក្រម៉ាពាក់ហ្នឹងក។

កៈ រួចយើងមិនយកក្រម៉ាចងហ្នឹងជើងទៅ?

ខៈ ចងរត់កើតក្រម៉ាមួយចងរត់កើតចងជាប់ជើងរត់កើត។

កៈ អ៊ូ!

ខៈ វេទនាណាស់ទំរាំនេះហ្នឹងលោកគ្រូពិបាកណាស់ជាតិនេះ។

កៈ អ៊ូ!

ខៈ ពិបាករហូត។

កៈ ចុះមីងនៅពេលដែរយើងជិតដាច់ប៉ុលពតយើងមើលម៉េចបានដឹងថាដាច់ប៉ុលពតទៅមីង?

ខៈ កាលដាច់ប៉ុលពតណុងទូកមិនដឹងទូកស្អីទេប្រាប់ទូកមួយគ្រាប់ធំហាសណាស់ស្រាប់តែគេថាដាច់ហើយប៉ុលពតដាច់ហើយទៅស្រុកទៅទៅទេសវិញចឹង។

កៈ បាទមីង!

ខៈ ដល់ចឹងទៅម៉ែខ្ញុំហ្នឹងរៀបចំបង្វេចរៀបចំអីមកស្រុកយើងវិញហ្នឹងហាស!

កៈ អ៊ូ!

ខៈ មកស្រុកហ្នឹងគៀនជ្រៃហ្នឹងហាស!

កៈ បាទមីងបាទ!

ខៈ មកដល់ណុងចាប់ផ្តើមធ្វើនុំបញ្ចុះហ្នឹងហាសក្ទួយលក់ស្ករលក់អីហ្នឹងហាស!

កៈ បាទមីងអ៎ូចឹងពិបាកដែរណោះមីងណេះ?

ខៈ ពិបាកខ្លាំងម៉ងដើរសុំផ្ទះគេនៅ។

កៈ ចុះអើកាលដាច់ប៉ុលពតដំបូងៗយើងដូចជាយើងមករត់មករកផ្ទះយើងវិញណោះមីង?

ខៈ មកស្រុកវិញ។

កៈ ប៉ុន្តែអើផ្ទះរបស់យើងអត់អីទេណោះគេអត់យកទៅធ្វើអី?

ខៈ អត់មានផ្ទះផងមកដល់សុំផ្ទះគេនៅពីរឆ្នាំសុំផ្ទះគេនៅបឹងអំបោសហ្នឹង!

កៈ បាទមីងបាទ!

ខៈ នៅចាំដល់ពេលនេះទៅគាត់មកពីរៀនឪពុកហ្នឹងគាត់មកពីរៀនវត្តក្នុងហ្នឹងមកសុំដីពូតាឡាចហ្នឹងធ្វើផ្ទះ។

កៈ បាទមីង!

ខៈ ធ្វើផ្ទះសសរប្ញស្សីហ្នឹងហាសត្រឹមចង្កេះហ្នឹងហាស!

កៈ បាទមីងបាទ!

ខៈ ធ្វើនៅ។

កៈ រួចចុះយើងនៅយើងមកគ្រាន់តែចេញពីប៉ុលពតដំបូងយើងមកធ្វើស្រែរួមមែនទេមីងណោះ?

ខៈ ធ្វើស្រែរួមធ្វើរួមទៅយូរទៅបានតិចទៅបានគេចែករបបអោយយើងធ្វើដោយខ្លួន។

កៈ អ៎ូបាទអ៊ុំបាទចុះពេលហ្នឹងយើងគិតថាម៉េចដែរមីងមានការលំបាកអីទៅ?

ខៈ លំបាកដូចខ្ញុំថា។

កៈ បាទមីងហើយចុះពេលយើងធ្វើស្រែរួមរយះពេលប៉ុន្មានបានគេចែកស្រែអោយយើងផ្ទាល់ខ្លួនមីង?

ខ៖ រួមលំបាកពីរវស្សាហើយហ្នឹងបានគេចែកអោយហ្នឹងហាសពីរវស្សាបីរវស្សាហ្នឹងបានគេចែកស្រែអោយយើងធ្វើដោយខ្លួន។

ក៖ ចឹងហោសមីង?

ខ៖ ធ្វើដោយខ្លួនក៏ធ្វើមិនឆ្អែតដែរម៉ានៅតែខ្វះចុងឆ្នាំចឹងយើងលក់ដូរអីផ្សំទៅល្មមបានគ្រប់ៗហោស!

ក៖ អ៊ូបាទមីងបាទចុះដល់ពេលតាំងពីយើងបែកមកយើងពិបាករហូតណោះមីងណោះរហូតទាល់មីងការ?

ខ៖ ពិបាករហូតទាល់តែមានប្ដីហ្នឹងក៏ពិបាកទាល់តែរៀងចាស់តិចហ្នឹងបានរៀងស្រួលតិចវិញហ្នឹង!

ក៖ អ៊ូពេលដែរមីងមានប្ដីដំបូងមីងគិតថាមានការលំបាកអីយើងចាប់ដៃគ្នារកស៊ីដំបូងមីង?

ខ៖ ហ្នឹងហើយពិបាករកស៊ីចិញ្ចឹមកូនធាក់កង់ទូលល្អីដដែរហ្នឹង!

ក៖ ចឹងហោសមីង?

ខ៖ ទូលលក់បន្លែលក់ខ្ទៅលក់អីប្រទះអីលក់ហានឹងទៅខាងស្រែហោស!

ក៖ អ៊ូបាទមីង!

ខ៖ ទូលល្អីទៅ។

ក៖ បាទមីងបាទរួចប្ដីទៅធ្វើស្រែធ្វើអីទៅ?

ខ៖ ធ្វើស្រែធ្វើការ។

ក៖ អ៊ូ!

ខ៖ រកអីធ្វើហ្នឹងចឹង។

ក៖ បាទមីងបាទចុះមីងគិតថាពេលណាដែរយើងចាប់ផ្ដើមសំបូរសប្បាយយើងចាប់ផ្ដើមមានអារម្មណ៍ថាអ៊ូលែងមានអីហើយមីងយើងចាប់ផ្ដើមសប្បាយហាស?

ខ៖ ចាប់ផ្ដើមរៀងរីកចិត្តល្បាក់ត្រឹមពីរពាន់ ពីរពាន់ប្រាំមួយពីរពាន់ប្រាំពីរ។

ក៖ អូ៎!

ខ៖ រហូទមកដល់ឥឡូវ។

ក៖ បាទមីងបាទអាហ្នឹងយើងចាប់ផ្ដើមមានអារម្មណ៍ថា..?

ខ៖ ស្ងាត់តិចរៀងដូចថារកព្រោះយើងមានស៊ីដែរចឹងហាសវាអត់មានទេគ្រាន់តែថាគ្រាន់តែមានស៊ីគ្រប់គ្រាន់ចឹង។

ក៖ យើងរៀងធូរជាងមុនណេះមីងណេះ?

ខ៖ ចា៎រៀងធូរជាងមុន។

ក៖ បាទមីងបាទ!

ខ៖ វាមិនពិបាកដូចមុនមិនរកអត់ស៊ីហាស!

ក៖ បាទមីងចុះមីងគិតថាចឹងកាលមីងនៅរៀនហាស មីងធ្លាប់មានគោលបំណងថាមីងធំឡើងមីងចង់ធ្វើអីមួយមីងធ្លាប់គិតអត់មីង?

ខ៖ អត់ធ្លាប់គិតទេកាលណុងអត់ធ្លាប់គិតនឹកឃើញអីទេល្ងង់ណាស់ក្មេងជំនាន់ណុងនោះគ្មាននឹកគិតថាចង់ធ្វើអីៗគ្មាននឹកឃើញទេ។

ក៖ អូចឹងហោសមីង?

ខ៖ ចា៎នឹកឃើញតែរកអោយបានមកនៅស៊ីហូបចុកនៅក្នុងក្រុមគ្រួសារអោយតែគ្រប់គ្រាន់តែប៉ុណ្ណឹង អោយនឹកឃើញថាចង់ធ្វើអីរកអីដូចមិននឹកឃើញទៀតសោះ។

ក៖ អូ៎បាទមីងចុះមីងគិតថាបើសិនជាមានសំនួរចុងក្រោយមួយ បើចង់អោយមីងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយហាសមីងមីងមានពាក្យពេចន៍អីដែរចង់ផ្ដែផ្ញើរទៅពួកគាត់ទេមីង?

ខ៖ ចង់ផ្ដែផ្ដាំថាជំនាន់ក្រោយហ្នឹងគេធូរធារហើយមិនពិបាកដូចកាលជំនាន់មីងមុនទេ ឆ្អែតហើយរឿងក្រស្គាល់អស់ហើយ!

កៈ បាទមីង!

ខៈ ចង់ស្គាល់ចង់ទូលរែកម៉េចក៏ខ្ញុំស្គាល់ដែរកូនចៅក្រោយគេស្រួលហើយគេមិនពិបាកដូចជំនាន់ខ្ញុំទេ។

កៈ បាទមីងបាទ!

ខៈ ចាំ!

កៈ ចុះអើមីងធ្លាប់ទូន្មានព្រានប្រដៅពួកគាត់កុំអោយធ្វើអត់ល្អនៅក្នុងសង្គមដូចជក់គ្រឿងញៀនដូចអើធ្វើអីដែរអត់ល្អហាស មីងធ្លាប់ទូន្មានព្រានប្រដៅពួកគាត់ទេណោះមីងណោះ?

ខៈ ប្រដៅរាល់ថ្ងៃ។

កៈ អូ៎!

ខៈ ទើបីវាមិនទាន់មានកូនក៏ប្រដៅ។

កៈ ឥឡូវក៏ដោយហោសមីង?

ខៈ ចាំឥឡូវហ្នឹងប្រដៅរាល់តែថ្ងៃទាំងកូន..។

កៈ ទាំងចៅទាំងអី?

ខៈ ទាំងចៅប៉ុនចៅវាតូចៗអើបួនឆ្នាំប្រាំឆ្នាំបើកូនវាអាយុម្ភៃសាមអីចឹងហាសណាស់។

កៈ បាទមីងបាទ!

ខៈ គឺឡូវានេះជ្រុលខុសគ្នាខុសអីចឹងប្រដៅកូនកុំអោយដើរផ្លូវហ្នឹងសង្គមគេស្អប់ខ្ពើមអោយតែរកស៊ីតាមសុចរឹតទៅបានប៉ុន្មានស៊ីប៉ុណ្ណឹងទៅ។

កៈ យើងចេះតែណែនាំរាល់ថ្ងៃហាសណោះមីង?

ខៈ ចាំណែនាំរាល់ថ្ងៃប្រាប់រាល់ថ្ងៃហ្នឹង!

កៈ អូ៎បាទ!

ខ៖ ប៉ុនកូនអត់មានធ្វើចឹងផង។

ក៖ បាទមីងបាទចុះមីងគិតថាមីងធ្លាប់មានអើទូន្មានទៅពួកគាត់ថានៅពេលដែរមីងនៅតូចមីងមានគោលបំណងចង់ធ្វើអីមួយដល់ពេលកូនៗរឺមួយក៏ចៅៗមីងចង់អោយសំរេចនូវគោលបំណងមីងអីហាស?

ខ៖ ចា៎!

ក៖ ធ្លាប់ប្រាប់ទេមីង?

ខ៖ អត់ធ្លាប់ប្រាប់ផងគ្រាន់តែប្រាប់ថាអោយប្រឹងរកស៊ីទៅកុំអោយក្រអីចឹងក្រពិបាកណាស់ជំនាន់ម៉ែទូលល្អីផុកត្រឹមជង្គង់ត្រឹមចង្កេះអូសទាញម៉េចស្គាល់អស់ហើយកុំអោយកូនចឹងអោយគ្រាន់បើជាងម៉ែទៅ។

ក៖ បាទមីងបាទ!

ខ៖ ប៉ុនកូនគ្រាន់បើរាល់ថ្ងៃវាបានមួយគ្រប់គ្រាន់វាដែរកូនហ្នឹងអត់ទេពិបាកតែយើងទេ។

ក៖ អូ៎បាទមីងបាទចឹងមានពាក្យពេចន៍អីដែរមីងចង់ផ្តាំផ្ញើរផ្សេងពីហ្នឹងទៀតទេមីង?

ខ៖ មានផ្តាំផ្ញើរស្អីទេ។

ក៖ អូ៎បាទមីងចឹងចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំពិភាក្សាជាមួយមីងទាក់ទងពីប្រវត្តិរបស់មីង ហើយខ្ញុំហ្នឹងដាក់ការសម្ភាសទាំងអស់នេះទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយកូនៗចៅៗរបស់មីងបានស្គាល់បានដឹង ចឹងចុងក្រោយខ្ញុំសុំការអនុញ្ញាតិពីមីងដើម្បីដាក់ការសម្ភាសពីមីងដើម្បីដាក់ការសម្ភាសមួយហ្នឹងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយកូនៗចៅរបស់មីងបានទេមីង?

ខ៖ បានតើ!

ក៖ អូ៎បានណេះមីង?

ខ៖ ចា៎!

ក៖ អត់អីទេណេះមីង?

ខ៖ ចាំ!

ក៖ បាទចឹងអរគុណច្រើនមីង។

ខ៖ ចាំ។